ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**************

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ:៤០៦/១១.៥.២០១១
សាលដីកា
លេខ: ៧៥ ក្រ.III.ស/១១.៩.២០១៣

# គោរពនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted]

<u>ក្រឡាបញ្ជី</u>

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៤០៦ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ ដែលមាន:

ជនជាប់ចោទឈ្មោះ [redacted] សុខា ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរៈធ្វើស្រែ កើតនៅ និងរស់នៅ [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ)។

<u>ត្រូវចោទពីបទ:</u> រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅភូមិស្តីលើ ឃុំព្រែកហ្លួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៩៤, ១០៤, ៣៩១ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ភេទស្រី អាយុ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរៈលក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិស្តីលើ ឃុំព្រែកហ្លួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

## <u>ដំណើររឿងមានដូចតទៅ:</u>

កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៨ ឈ្មោះ [redacted] ចន្ថា បានលេងតុងទីនមួយក្បាលជាមួយឈ្មោះ [redacted] សុខា ដោយភាគហ៊ុន១០០$ ១ខែដេញម្តង មានសមាជិកចំនួន២៥នាក់។ នៅពេលលេងឈ្មោះ [redacted] ចន្ថា



Scanned with CamScanner

បានបង់ប្រាក់រយៈពេល២២ខែ ក៏ដេញ តែដេញមិនបាន ដោយមេតុងទីនឈ្មោះ [redacted] សុខា ចេះតែថាអ្នកនេះដេញបាន អ្នកនោះដេញបាន តាមការសាកសួរ មេលួចដេញឈ្មោះកូនតុងទីន។ ដោយឈ្មោះក្នុងបញ្ជីនៅសល់បីនាក់ ហើយអ្នកដែលមកដេញប្រមាណ១០នាក់ មេក៏ប្រកាសរំលាយ ហើយគេចខ្លួនបាត់តែម្តង។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២០ «ផ» ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១. ផ្តន្ទាទោសឈ្មោះ [redacted] សុខា ភេទស្រី អាយុ២៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ (មួយឆ្នាំ) ប៉ុន្តែត្រូវអនុវត្តទាសព្យួរ។

ពីបទ រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅភូមិស្តីលើ ឃុំព្រែកហ្លួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩៤, ១០៤, ៣៩១ នៃក្រមព្រហ្មទណ្ឌ។

២. បង្គាប់ឲ្យឈ្មោះ [redacted] សុខា ភេទស្រី អាយុ២៦ឆ្នាំ សងសំណងជាប្រាក់ចំនួន៨៤៥$(ប្រាំបីរយសែសិបប្រាំដុល្លាអាមេរិក) ឲ្យទៅឈ្មោះ [redacted] ចន្ថា ជាដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីពេលសាលក្រមនេះបានចូលជាស្ថាពរ,

៣. សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី, ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៨៤ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សុខា ជាជនជាប់ ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២០ «ផ» ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូង ខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## **នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សា សង្ខេបអង្គហេតុរឿងជូនអង្គសវនាការ

ជនជាប់ចោទឈ្មោះ [redacted] សុខា ឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ព្រោះខ្លួនមិនមានលទ្ធភាពសងទាំងអស់ទេ ខ្លួនសុំសងក្នុងមួយខែ១០$ ពេលខ្លួនរកប្រាក់ចំណូលបានច្រើនខ្លួនបន្ថែមទៀត, ខ្លួនទទួលស្គាល់កំហុស តែខ្លួនមិនមានលទ្ធភាព។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ឆ្លើយថា ខ្លួនមិនសុខចិត្តទេ ខ្លួនលេងបាន១៩ខែ និងបានបង់ប្រាក់ ចំនួន ១.៩០០$, នៅពេលដេញម្តងៗ មេតែងថា បានទៅអ្នកនេះ បានទៅអ្នកនោះ និងចុង



Scanned with CamScanner

ក្រោយថា គេដេញអស់ ហើយ ស្រាប់តែពេលដេញ មានកូនតុងទីនមកដេញ រហូត១០នាក់។ សំណូមពរ សុំដូចសាលាដំបូងខេត្ត។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ដោយជនជាប់ចោទមានកាតព្វកិច្ចប្រមូលប្រាក់តុងទីនយកទៅឲ្យកូនតុងទីន ដែលដេញបាន ប៉ុន្តែ ខ្លួន``បានយកប្រាក់នេះទៅជាប្រយោជន៍ផ្ទាល់ខ្លួន។ សូមសភាព្រហ្មទណ្ឌតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២០ «ផ» ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបាត់ដំបង។

## សំអាងហេតុ

១. បណ្តឹងឧទ្ធរណ៍លេខ ៤៤ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ[redacted]សុខា ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយជនជាប់ចោទនៅសាលាដំបូងថា ខ្លួនជាមេតុងទីនពីរខ្សែ, ក្នុងពីរខ្សែនេះ ខ្សែទី១មាន សមាជិក២៥នាក់ ចាប់លេងពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៨ តម្លៃ១០០$, មួយខែដេញម្តង។ ក្បាលនេះកូន ដេញអស់ពី១៣ ទៅ១៤នាក់, ខ្លួនរំសាយនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ ដោយកូនដេញបាន ហើយមិនបង់ ប្រាក់ឲ្យខ្លួន ធ្វើឲ្យខ្លួនគ្មានប្រាក់ឲ្យសមាជិក ដែលមិនទាន់ដេញ។ ដើមបណ្តឹងរដ្ឋប្បវេណីលេងបានតែ១៣ខែ ឈប់, ខ្លួនទទួលស្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីបានបង់ប្រាក់ចំនួន៦៩០$(ប្រាំមួយរយកៅសិបដុល្លា- អាមេរិក) ខ្លួនមិន ដែលបានដេញតុងទីនយកខ្លួនឯងទេ។

៣. តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីថា ខ្លួនលេងបាន១៩ខែ និងបានបង់ប្រាក់ចំនួន ១.៩០០$, នៅ ពេលដេញម្តងៗ មេតែងថា បានទៅអ្នកនេះ បានទៅអ្នកនោះ និងចុងក្រោយថា គេដេញអស់ហើយ ស្រាប់តែ ពេលដេញ មានកូនតុងទីនមកដេញ មានរហូត១០នាក់។

៤. មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅភូមិស្តីលើ ឃុំព្រែកហ្លួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌមានចែង និង ឲ្យផ្តន្ទាទោសតាមមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

៥. សំអាងហេតុ និងសេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ២០ «ផ» ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបាត់ដំបង មានភាពច្បាស់លាស់ និងត្រឹមត្រូវ គួរតម្កល់ទុកជាបានការ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៤ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ[redacted]សុខា ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្អែកលើអង្គគតិច្បាប់។



Scanned with CamScanner

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២០ «ជ» ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការ ពេញទាំងមូល។

៣. សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី, បើកផ្លូវសាទុក្ខ០១ខែ គិតចាប់ពីថ្ងៃប្រកាសតទៅ។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ ៥**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ១២ ខែ ៦ ឆ្នាំ ២០១៤
ក្រឡាបញ្ជី



Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា

សាលាឧទ្ធរណ៍ ជាតិ សាសនា ព្រះមហាក្សត្រ

************** **************

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៤០៦ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១

## ដីកាសម្រេច

## ប្រធានក្រុមប្រឹក្សាជំនុំជម្រះទី ៣

- បានឃើញ មាត្រា ៦០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៦ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍។
- បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៧៥ ក្រ.III.ស ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ។
- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២០ «ជ» ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបាត់ដំបង ។

ក្រោយពីបានពិនិត្យសាលដីកាខាងលើឡើងវិញឃើញថាៈ សាលដីកានេះ មានកំហុសដោយអចេតនាក្នុងទំព័រទី១ នៃសាលដីកា ដោយចុះកាលបរិច្ឆេទ ថ្ងៃនៃសំណុំរឿង របស់សាលាឧទ្ធរណ៍ខុស គប្បីសាលាឧទ្ធរណ៍កែតម្រូវឡើងវិញ។

### ហេតុដូច្នេះ

### សម្រេច

កែតម្រូវកាលបរិច្ឆេទ ថ្ងៃនៃសំណុំរឿង ក្នុងទំព័រទី១ នៃសាលដីកាព្រហ្មទណ្ឌលេខ ៧៥ ក្រ.III.ស ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដូចខាងក្រោមៈ

សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៦ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ .របស់សាលាឧទ្ធរណ៍ ទៅជាសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៦ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ វិញ។

ចៅក្រមប្រឹក្សា
ហត្ថលេខាៈ ម្លូង សំណាង, ប៉ាក ច័ន្ទសំបូរ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខាៈ សំរិទ្ធិ សុផល

................................................................................................

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

សំរិទ្ធិ សុផល

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៤
ក្រឡាបញ្ជី

ភី...រិទ្ធី



Scanned with CamScanner